# ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ជំពូក ១
## ការអនុវត្តន៍ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

---

អគ្គលេខាធិការដ្ឋាន
អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន
អគារថ្មីផ្លូវលេខ ២៧៣ កែង ៥១៦ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ
ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១ | ០២៣-៨៨១-៤៩២
គេហទំព័រ: www.cmaa.gov.kh

# មាតិកា


មាតិកា ........ i
សេចក្ដីផ្ដើម ........ 1
ការអនុវត្តន៍ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា........ 2
១. ទ្រង់ទ្រាយ........ 2
២. វាក្យស័ព្ទ និងនិយមន័យ ........ 2
៣. សកម្មភាពកំចាត់មីន ........ 2
៤. គោលបំណងនៃស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា........ 4
៥. ការទទួលខុសត្រូវ និងកាតព្វកិច្ចថ្នាក់ជាតិ ........ 4
សន្ធិសញ្ញាអន្តរជាតិ ........4
៦. តម្រូវការផ្នែកច្បាប់........5
៧. ដែននៃការទទួលខុសត្រូវ........5
៧.១. អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ........5
៧.២. ប្រតិបត្តិករសកម្មភាពកំចាត់មីន........5
៧.៣. ប្រទេសផ្តល់ជំនួយ ........6

# សេចក្តីផ្តើម

វាក្យស័ព្ទ *"សកម្មភាពកំចាត់មីន"* គឺផ្តោតលើសកម្មភាពទាំងឡាយ ដែលរួមគ្នាសំដៅកាត់បន្ថយផលប៉ះពាល់សង្គម សេដ្ឋកិច្ច និងបរិស្ថាន ដែលបង្កឡើងដោយសារមីន ដូចជា ការអប់រំយល់ដឹងអំពីមីន ការអប់រំកាត់បន្ថយគ្រោះថ្នាក់ដោយសារមីន ការបោសសំអាតមីន កិច្ចសង្គ្រោះជនពិការដោយសារមីន និងការគាំទ្រទាំងស្រុងដល់ការហាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទ និងការកំទេចចោលគ្រាប់មីនដែលមាននៅក្នុងស្តុក។

រាជរដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជា ជាប្រទេសហត្ថលេខីលើអនុសញ្ញាឆ្នាំ ១៩៩៧ ស្តីពី **"ការហាមប្រើប្រាស់ ការស្តុក ការផលិត ការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញចោល"** (យោងសន្ធិសញ្ញាហាមប្រើប្រាស់គ្រាប់មីន ឬអនុសញ្ញាអូតាវ៉ា)។

ច្បាប់ហាមប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទ ត្រូវបានអនុម័តដោយសភាជាតិនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី ២៨ ខែមេសា ឆ្នាំ១៩៩៩។ ច្បាប់នេះអនុវត្តទៅតាមតម្រូវការនៃសន្ធិសញ្ញាអន្តរជាតិ អនុសញ្ញា កិច្ចព្រមព្រៀង និងលិខិតូបករណ៍នានា ដែលទាក់ទងនឹងមីនប្រឆាំងមនុស្សគ្រប់ប្រភេទ។

ព្រះរាជក្រឹត្យចុះថ្ងៃទី ០៤ ខែកញ្ញា ឆ្នាំ២០០០ បានបង្កើតឱ្យមានអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន (ហៅកាត់ថា អាជ្ញាធរមីន) ដែលជាស្ថាប័ននិយតករតំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា ទទួលបន្ទុករាល់បញ្ហាដែលទាក់ទងនឹងមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ គ្រប់គ្រងសកម្មភាពកំចាត់មីន និងគាំទ្រដល់កិច្ចសង្គ្រោះជនពិការដោយសារមីន។

សកម្មភាពកំចាត់មីន និងសកម្មភាពផ្សេងៗដែលពាក់ព័ន្ធ មិនអាចប្រព្រឹត្តទៅដោយឯកកោបានឡើយ គឺត្រូវដាក់បញ្ចូលជាមួយនូវការអនុវត្តន៍សកម្មភាពមនុស្សធម៌ និងកម្មវិធីអភិវឌ្ឍន៍នានា។ សកម្មភាពកំចាត់មីនតម្រូវឱ្យមានផែនការគ្រប់គ្រងថ្នាក់ជាតិ និងមូលដ្ឋាន ដោយមានកិច្ចសហការជាមួយអង្គការជាតិ-អន្តរជាតិ អង្គការពាណិជ្ជកម្ម អង្គការក្រៅរដ្ឋាភិបាល និងអង្គភាពយោធាដែលកំពុងប្រតិបត្តិការក្រោមរូបភាពផ្សេងៗ ហើយស្ថិតក្រោមការត្រួតពិនិត្យរបស់អាជ្ញាធរមីន។

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា (CMAS) គឺជាទម្រង់បទបញ្ញត្តិមួយសម្រាប់រាល់សកម្មភាពកំចាត់មីននៅព្រះរាជាណាចក្រកម្ពុជា ដែលមានអាជ្ញាធរមីនជាអ្នកទទួលខុសត្រូវក្នុងការធ្វើសេចក្តីព្រាងការត្រួតពិនិត្យឡើងវិញ និងការកែប្រែទៅតាមសភាពការណ៍ ដើម្បីឆ្លើយតបទៅនឹងការផ្លាស់ប្តូរទាំងឡាយដោយផ្អែកលើស្តង់ដាសកម្មភាពកំចាត់មីនអន្តរជាតិ (IMAS)។

# ការអនុវត្តន៍ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

## ១. ទ្រនំទ្រាយ

ឯកសារនេះបញ្ជាក់យ៉ាងច្បាស់ អំពីតួនាទីរបស់ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា និងបង្កើតគោលការណ៍ណែនាំនានា ដើម្បីប្រើប្រាស់ឱ្យបានត្រឹមត្រូវ និងសមស្របដោយអាជ្ញាធរមីន អង្គការជាតិ-អន្តរជាតិ ប្រទេសផ្តល់ជំនួយ និងប្រតិបត្តិករនានាដែលពាក់ព័ន្ធក្នុងការរៀបចំផែនការ និងការអនុវត្តន៍សកម្មភាពកំចាត់មីននៅកម្ពុជា ទាំងនៅទីបញ្ជាការ និងតាមការដ្ឋាន។

## ២. វាក្យស័ព្ទ និងនិយមន័យ

"ស្តង់ដា" គឺជាតម្រូវការនានាដែលចាំបាច់ ច្បាស់លាស់ ឬលក្ខខណ្ឌជាក់លាក់ដទៃទៀត ដែលត្រូវប្រើប្រាស់ជាប្រចាំ ដើម្បីធ្វើឱ្យសម្ភារៈ ផលិតផល ដំណើរការ និងសេវាកម្មដែលត្រូវយកមកប្រើនោះចំគោលដៅកំណត់។ ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា មានគោលបំណងបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពនៅក្នុងសកម្មភាពកំចាត់មីនដោយពណ៌នាពីនីតិវិធី និងការអនុវត្តន៍នានាដែលសមស្រប និងត្រូវបានតម្រូវ ទាំងនៅទីបញ្ជាការ និងនៅតាមការដ្ឋាន។

ក្នុងស្តង់ដានេះ ពាក្យ "ត្រូវតែ គួរតែ និង បើអាច" ត្រូវបានប្រើប្រាស់ ដើម្បីបញ្ជាក់ពីកម្រិតនៃការអនុវត្តន៍ និងស្របទៅតាមភាសាដែលបានប្រើប្រាស់ និងការណែនាំនៅក្នុងអង្គការស្តង់ដាអន្តរជាតិ (ISO)។

ក) ពាក្យ "**ត្រូវតែ**" ត្រូវបានប្រើ ដើម្បីបញ្ជាក់ពីតម្រូវការចាំបាច់ វិធីសាស្ត្រ ឬភាពជាក់លាក់ ដែលត្រូវអនុវត្តឱ្យស្របទៅនឹងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។

ខ) ពាក្យ "**គួរតែ**" ត្រូវបានប្រើ ដើម្បីបញ្ជាក់ពីតម្រូវការ វិធីសាស្ត្រ ឬភាពជាក់លាក់ផ្សេងៗទៀតដែលបានស្នើឡើង។

គ) ពាក្យ "**បើអាច**" ត្រូវបានប្រើ ដើម្បីបញ្ជាក់ពីវិធី ឬមធ្យោបាយដែលអាចទទួលយកបាន។

ស្តង់ដា ឬបទដ្ឋានប្រតិបត្តិការ (SOPs) ជាសេចក្តីណែនាំ ដែលកំណត់ពីតម្រូវការ ឬជាវិធីសាស្ត្រដែលទើបបង្កើតថ្មីនៃការអនុវត្តន៍សកម្មភាព ឬកិច្ចប្រតិបត្តិការ ដែលមានគោលបំណងបង្កើតជាក្រឹត្យវិន័យ ឯកសណ្ឋានភាព និងស្ថេរភាព ដែលមានការទទួលស្គាល់ទៅតាមកម្រិតនៅក្នុងអង្គភាពនីមួយៗ ក្នុងគោលបំណងបង្កើនប្រសិទ្ធភាព និងសុវត្ថិភាពប្រតិបត្តិការ ដោយឆ្លុះបញ្ចាំងពីតម្រូវការ និងកាលៈទេសៈតាមមូលដ្ឋាន។

អក្ខរានុក្រមនៃពាក្យពេចន៍ទាំងស្រុង និងនិយមន័យដែលបានប្រើនៅក្នុងងស្តង់ដា នឹងត្រូវអនុម័តនៅពេលខាងមុខ។

## ៣. សកម្មភាពកំចាត់មីន

សកម្មភាពកំចាត់មីននៅកម្ពុជា គឺផ្តោតលើសកម្មភាពទាំងឡាយ ដែលរួមគ្នាសំដៅកាត់បន្ថយផលប៉ះពាល់សង្គម សេដ្ឋកិច្ច បរិស្ថាន ដែលបង្កឡើងដោយសារមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងកាត់បន្ថយគ្រោះថ្នាក់ដោយសារគ្រាប់មីនឱ្យដល់កម្រិតមួយ ដែលប្រជាពលរដ្ឋអាចរស់នៅដោយសុវត្ថិភាព ជាមួយនឹងការអភិវឌ្ឍន៍វិស័យសេដ្ឋកិច្ច សង្គមកិច្ច និងសុខាភិបាល ដោយមិនមានការភ័យខ្លាចគ្រោះថ្នាក់ដោយសារគ្រាប់មីន ហើយសេចក្តីត្រូវការរបស់ជនរងគ្រោះត្រូវបានដោះស្រាយ។

សកម្មភាពកំចាត់មីននៅកម្ពុជា ត្រូវបានបែងចែកជាបួនកម្មវិធី គឺ:

ក) ការអប់រំយល់ដឹងអំពីមីន និងយុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ និងការអប់រំដើម្បីកាត់បន្ថយគ្រោះថ្នាក់។

ខ) ការដោះមីន រួមមាន ការស្រាវជ្រាវចំការមីន/យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ ការធ្វើផែនទី ការដាក់ផ្លាកសញ្ញាសម្គាល់ និងការបោសសំអាតគ្រាប់មីន។

គ) កិច្ចសង្គ្រោះជនពិការដោយសារមីន រាប់បញ្ចូលទាំងការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្ម។

ឃ) ការគាំទ្រចំពោះការប្រឆាំងនឹងការប្រើប្រាស់គ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទ។

សកម្មភាពមួយចំនួនទៀត ដែលគាំទ្រដល់សកម្មភាពទាំងបួនខាងលើ រួមមាន ការវាយតម្លៃ ការធ្វើផែនការ ការប្រមូលផ្តុំ និងកំណត់អាទិភាពប្រភពធនធាន ការគ្រប់គ្រងពត៌មាន កិច្ចអភិវឌ្ឍជំនាញ ការបណ្តុះបណ្តាលផ្នែកគ្រប់គ្រង ការគ្រប់គ្រងគុណភាព និងការប្រើប្រាស់សម្ភារៈ ឧបករណ៍ប្រកបដោយប្រសិទ្ធភាព សមស្របនិងមានសុវត្ថិភាព។

## ៤. គោលបំណងនៃស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា នឹងសម្របសម្រួលដល់អាជ្ញាធរមីន ប្រតិបត្តិករដោះមីនជាតិ និងអន្តរជាតិ ក្នុងការបង្កើតគោលការណ៍ណែនាំបច្ចេកទេស និងបទដ្ឋានប្រតិបត្តិការ (SOPs) ដោយបង្កើតកម្រងឯកសារយោងនានាសម្រាប់ប្រើប្រាស់ក្នុងសកម្មភាពកំចាត់មីននៅកម្ពុជា ព្រមទាំងផ្តល់គោលការណ៍នានាសម្រាប់រៀបចំកិច្ចសន្យាតាមផ្លូវច្បាប់រវាងប្រទេសផ្តល់ជំនួយ និងប្រតិបត្តិករដោះមីនដែលអនុវត្តគម្រោង។

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា មិនមែនជាបទដ្ឋានប្រតិបត្តិការ ដែលពិពណ៌នាអំពីវិធីបោសសំអាតមីនដែលត្រូវអនុវត្តនៅតាមការដ្ឋានទេ។ វិធីសាស្ត្រការបោសសម្អាតមីន មានចែងដោយឡែក នៅក្នុងសេចក្តីណែនាំបច្ចេកទេសថ្នាក់ជាតិ និងបទដ្ឋានប្រតិបត្តិការរបស់ប្រតិបត្តិករដោះមីនដូចជា ច្បាប់ សេចក្តីណែនាំ និងការអនុវត្តន៍ជាក់ស្តែង។

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ត្រូវបានរៀបចំឡើងដើម្បីបង្កើនសុវត្ថិភាព និងប្រសិទ្ធភាពលើសកម្មភាពកំចាត់មីននៅកម្ពុជា និងផ្តល់ការណែនាំ ដើម្បីបង្កើតជាគោលការណ៍ ដោយកំណត់នូវលក្ខខណ្ឌនានា និងតម្រូវការថ្នាក់ជាតិផ្សេងៗ និងផ្តល់នូវកម្រងឯកសារយោងនានា ដែលលើកទឹកចិត្តដល់ប្រទេសផ្តល់ជំនួយ អ្នកគ្រប់គ្រងកម្មវិធីកំចាត់មីន គម្រោងកម្មវិធីនានា ដើម្បីសម្រេចគោលបំណងប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពតាមកម្រិតដែលបានព្រមព្រៀងរួច។

## ៥. ការទទួលខុសត្រូវ និងភាតព្វកិច្ចថ្នាក់ជាតិ

ការទទួលខុសត្រូវជាបឋមសម្រាប់សកម្មភាពកំចាត់មីន គឺជាបន្ទុករបស់រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន ដែលជាអ្នកទទួលបន្ទុកផ្នែកច្បាប់ ការគ្រប់គ្រង និងការសម្របសម្រួលសកម្មភាពកំចាត់មីននៅកម្ពុជា ព្រមទាំងបង្កើតលក្ខខណ្ឌថ្នាក់ជាតិ និងមូលដ្ឋាន ដែលជួយជម្រុញឱ្យការគ្រប់គ្រងសកម្មភាពកំចាត់មីនមានប្រសិទ្ធភាព។ នេះជាការទទួលខុសត្រូវសំខាន់បំផុតសម្រាប់គ្រប់ដំណាក់កាលនៃកម្មវិធីកំចាត់មីននៅក្នុងដែនកំណត់នៃប្រទេសកម្ពុជា រួមមាន ការអភិវឌ្ឍន៍ និងការរក្សាស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា និងគោលការណ៍ណែនាំបច្ចេកទេសនានា ។

### សន្ធិសញ្ញាអន្តរជាតិ

ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា បញ្ជាក់ច្បាស់ពីសន្ធិសញ្ញាធំៗពីរនៅក្នុងច្បាប់អន្តរជាតិពាក់ព័ន្ធដល់បញ្ហាគ្រាប់មីនដែលមានរាជរដ្ឋាភិបាលកម្ពុជាជាប្រទេសហត្ថលេខីមួយដែរនោះគឺ:

ក) អនុសញ្ញាឆ្នាំ១៩៩៧ ស្តីពី **"ការហាមប្រើប្រាស់ ការស្តុកទុក ការផលិត ការដឹកជញ្ជូន និង ការបំផ្លាញចោលគ្រាប់មីនប្រឆាំងមនុស្សគ្រប់ប្រភេទ"** (សន្ធិសញ្ញាហាមប្រើប្រាស់គ្រាប់មីន និងអនុសញ្ញាអូតាវ៉ា)។

ខ) ការធ្វើវិសោធនកម្មពិធីសារទី២ នៃអនុសញ្ញាអាវុធធម្មតារបស់អង្គការសហប្រជាជាតិ ស្តីពី "**ការហាមប្រាម ឬការដាក់កម្រិតលើការប្រើប្រាស់គ្រាប់មីន មីនអន្ទាក់ និងឧបករណ៍ផ្ទេរផ្សេងទៀត**"។

ប្រការដែលបានចែងក្នុងស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា មិនអាចបំពេញជំនួសកាតព្វកិច្ចទាំងស្រុងដែលបានពិពណ៌នានៅក្នុងសន្ធិសញ្ញាហាមប្រើប្រាស់គ្រាប់មីន និងការធ្វើវិសោធនកម្មពិធីសារទី២បានឡើយ។

## ៦. តម្រូវការផ្នែកច្បាប់

រាជរដ្ឋាភិបាលកម្ពុជា តាមរយៈអាជ្ញាធរមីន បានអនុម័តស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជាដែលជាច្បាប់សម្រាប់គ្រប់គ្រងសកម្មភាពកំចាត់មីននៅក្នុងព្រះរាជាណាចក្រកម្ពុជា។ តម្រូវការនានានៃស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា នឹងបញ្ជាក់ច្បាស់លាស់នៅក្នុងកិច្ចសន្យា ឬលិខិតូបករណ៍ស្របច្បាប់ផ្សេងទៀតដូចជា អនុស្សារណៈនៃការយោគយល់គ្នា ឬកិច្ចព្រមព្រៀង។ នៅក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងនីមួយៗ ត្រូវបញ្ជាក់ពីការអនុវត្តន៍ស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា ចំពោះសំណើគម្រោងកម្មវិធីនីមួយៗ និងត្រូវធ្វើឱ្យស្របទៅតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា។ កិច្ចសន្យានេះ នឹងគ្របដណ្តប់លើបញ្ហាទូទៅដូចជា សុវត្ថិភាព សុខុមាលភាព តម្រូវការ បរិស្ថាន ឱកាសស្មើភាពគ្នា និងកម្រិតប្រាក់បៀវត្ស ព្រមទាំងបទបញ្ញត្តិជាក់លាក់ ដែលទាក់ទងដល់ការអនុវត្តន៍សកម្មភាពកំចាត់មីន។

## ៧. ដែននៃការទទួលខុសត្រូវ

### ៧.១. អាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

អាជ្ញាធរមីន ទទួលខុសត្រូវក្នុងការជានាឱ្យមានលក្ខខណ្ឌនានា ដើម្បីជម្រុញឱ្យការគ្រប់គ្រងគម្រោងកម្មវិធីកំចាត់មីនឱ្យមានប្រសិទ្ធភាព ដោយការបង្កើត និងគ្រប់គ្រងកម្មវិធីសកម្មភាពកំចាត់មីនថ្នាក់ជាតិនៅកម្ពុជា។

បន្ថែមលើការបង្កើត និងការថែរក្សាស្តង់ដាថ្នាក់ជាតិ អាជ្ញាធរមីនត្រូវបង្កើត ច្បាប់វិន័យ និងនីតិវិធីនានាសម្រាប់ការគ្រប់គ្រងកិច្ចប្រតិបត្តិការសកម្មភាពកំចាត់មីន ស្របតាមស្តង់ដាសកម្មភាពកំចាត់មីនកម្ពុជា។

ចំពោះសកម្មភាពសង្គ្រោះជនពិការដោយសារមីន អាជ្ញាធរមីនត្រូវតាមដានភ្នាក់ងារដែលពាក់ព័ន្ធ រួមមានក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រុមប្រឹក្សាសកម្មភាពជនពិការ (DAC) ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិ ដោយតម្រូវឱ្យស្ថាប័នទាំងនោះ ដាក់ជូនអាជ្ញាធរមីននូវផែនការសកម្មភាពជាយុទ្ធសាស្ត្រ និងរបាយការណ៍ស្តីពីការរីកចម្រើននានា។

ការទទួលខុសត្រូវទាំងស្រុងរបស់អាជ្ញាធរមីន មានចែងនៅក្នុងព្រះរាជក្រឹត្យលេខ ន.ស/រកត/០៩០០/១៦០ ស្តីពី "**ការបង្កើតអាជ្ញាធរកម្ពុជា គ្រប់គ្រងសកម្មភាពកំចាត់មីន និង សង្គ្រោះជនពិការដោយសារមីន**" ហៅកាត់ថា **អាជ្ញាធរមីន** (CMAA) និងអនុក្រឹត្យលេខ ៧៦/អនក្រ/បក ស្តីពី "**ការរៀបចំ និងការប្រព្រឹត្តិទៅរបស់អាជ្ញាធរមីន**"។

### ៧.២. ប្រតិបត្តិករសកម្មភាពកំចាត់មីន

អង្គការនានា ដែលជាប់ពាក់ព័ន្ធជាមួយសកម្មភាពកំចាត់មីននៅកម្ពុជា ត្រូវបង្កើតបទដ្ឋានប្រតិបត្តិការ (SOPs) សេចក្តីណែនាំ និងក្បួនច្បាប់នានា ស្របតាមស្តង់ដាជាតិសកម្មភាពកំចាត់មីន ដើម្បីជម្រុញឱ្យកម្មវិធីកំចាត់មីន ប្រព្រឹត្តទៅដោយប្រសិទ្ធភាព សក្តានុពលភាព និងសុវត្ថិភាពពេញលេញ។ អាជ្ញាធរមីន នឹងត្រួតពិនិត្យយ៉ាងទៀងទាត់ចំពោះការអនុវត្តន៍ដែលមានចែងក្នុងឯកសារទាំងនេះ។

**ចំណាំ:** វាក្យស័ព្ទ "**ប្រតិបត្តិករដោះមីន**" ដែលជាប់ពាក់ព័ន្ធក្នុងសកម្មភាពកំចាត់មីននៅកម្ពុជា រាប់បញ្ចូលទាំងអង្គការក្រៅរដ្ឋាភិបាលថ្នាក់ជាតិ និងអន្តរជាតិ អង្គការពាណិជ្ជកម្មជាតិ និងអន្តរជាតិ ស្ថាប័នជាតិ ដូចជាមជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា (CMAC) និងកងវិស្វកម្មនៃកងយោធពលខេមរភូមិន្ទ។

### ៧.៣. ប្រទេសផ្តល់ជំនួយ

ប្រទេសផ្តល់ជំនួយ សំដៅលើរដ្ឋាភិបាល អង្គការប្រចាំតំបន់ និងមូលនិធិទំនុកចិត្តអន្តរជាតិ ដែលផ្តល់មូលនិធិភាគច្រើនសម្រាប់សកម្មភាពកំចាត់មីន ដូច្នោះភ្នាក់ងារផ្តល់ជំនួយគឺជា ផ្នែកមួយនៃដំណើរការគ្រប់គ្រងដែលមានការទទួលខុសត្រូវ ការធានាចាត់ចែងគម្រោងកម្មវិធីឱ្យមានប្រសិទ្ធភាព ដោយអនុលោមទៅតាមស្តង់ដាជាតិនេះ។ ការធ្វើសេចក្តីព្រាងឯកសារកិច្ចសន្យានានាជាមួយប្រតិបត្តិករដោះមីន ត្រូវធានាថា អង្គការដែលត្រូវបានជ្រើសរើសនោះ មានសមត្ថភាពបំពេញទៅតាមលក្ខខណ្ឌតម្រូវថ្នាក់ជាតិ ដោយមានប័ណ្ណទទួលស្គាល់ និងអាជ្ញាប័ណ្ណត្រឹមត្រូវគោរពតាមគោលការណ៍ណែនាំសម្រាប់ការគ្រប់គ្រងគុណភាព និងអនុវត្តផែនការដោយធ្វើការពិគ្រោះយោបល់ជាមួយអាជ្ញាធរមីនកម្ពុជា។